Los Angeles County
Registrar-Recorder/County Clerk

សេចក្តីប្រកាសសិទ្ធិងកកត្តជននៃអ្នកបោះឆ្នោត

ចូរចាំ

- កន្លែងបោះឆ្នោត បើកទ្វារនៅថ្ងៃបោះឆ្នោតចាប់ពីម៉ោង 7:00 ព្រឹក ដល់ម៉ោង 8:00 យប់។
- លោកអ្នកអាចរកកន្លែងបោះឆ្នោត និងព័ត៌មានមានតម្លៃផ្សេងៗទៀតជាច្រើននៅតាមបណ្តាញគេហទំព័រ **www.LAVOTE.net**

- លោកអ្នកមានសិទ្ធិបោះឆ្នោត បើសិនជាលោកអ្នកជាអ្នកបោះឆ្នោតបានចុះឈ្មោះ។
- លោកអ្នកមានសិទ្ធិទទួលជំនួយក្នុងការបោះឆ្នោតរបស់លោកអ្នក។
- លោកអ្នកមានសិទ្ធិបោះឆ្នោតបណ្តោះអាសន្ន បើសិនជាឈ្មោះលោកអ្នក មិនមានចុះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត។
- លោកអ្នកមានសិទ្ធិផ្ញើសន្លឹកឆ្នោតបោះផ្ញើតាមសំបុត្រដែលគូសរួចហើយនោះ ទៅមណ្ឌលបោះឆ្នោតមួយណាក៏ដោយនៅក្នុងខោនធី។
- លោកអ្នកមានសិទ្ធិបោះឆ្នោត បើសិនជាលោកអ្នកនៅក្នុងជួរនៅកន្លែងបោះឆ្នោតមុនម៉ោង 8:00 យប់។
- លោកអ្នកមានសិទ្ធិទទួលសម្ភារៈបោះឆ្នោតជាភាសាផ្សេងទៀត។ ខោនធី L.A. ផ្តល់សម្ភារៈបោះឆ្នោត 10 ភាសាផ្សេងៗគ្នា។
- លោកអ្នកមានសិទ្ធិបោះឆ្នោតសំងាត់ដោយ្មានការបំភិតបំភ័យ។
- លោកអ្នកមានសិទ្ធិសួរសំណួរ អំពីនិតិវិធីបោះឆ្នោត និងសង្កេតមើលដំណើរការបោះឆ្នោត។
- លោកអ្នកមានសិទ្ធិទទួលសន្លឹកឆ្នោតថ្មី បើសិនជាលោកអ្នកនឹកថាលោកអ្នកមានការភ័ន្តច្រឡំ មុននឹងលោកអ្នកទំលាក់សន្លឹកឆ្នោតនោះទៅក្នុងប្រអប់ឆ្នោត។
- លោកអ្នកមានសិទ្ធិធ្វើរបាយការណ៍នូវសកម្មភាពខុសច្បាប់ ឬសកម្មភាពក្លែងបន្លំអ្វីមួយទៅឱ្យមន្ត្រីផ្នែកបោះឆ្នោត ឬរាយការណ៍ទៅការិយាល័យលេខាធិការរដ្ឋ។

www.LAVOTE.net

ដើម្បីស្នើសុំសម្ភារៈបោះឆ្នោតជាភាសា ចិន ជប៉ុន កូរ៉ៃ អេស្ប៉ាញ៉ុល
តាហ្គាឡុក រៀតណាម ហ៊ុនឌី ខ្មែរ ឬថៃ សូមទូរស័ព្ទមកយើង 1.800.481.8683 ។

Khmer